## ស្ថានទូតអូស្ត្រាលី
## រាជធានីភ្នំពេញ

## សេចក្តីប្រកាសព័ត៌មាន

# ប្រទេសអូស្ត្រាលីផ្តល់ថវិការបន្ថែម
# ដល់អង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ឯកឧត្តម ព្រឹទ្ធសមាជិក បប់ ខារ** រដ្ឋមន្ត្រីក្រសួងការបរទេសអូស្ត្រាលី បានប្រកាសនៅថ្ងៃទី១៨ ខែមិថុនា នេះថា ប្រទេសអូស្ត្រាលីនឹងផ្តល់ថវិការបន្ថែមចំនួន៣,២៥លានដុល្លាអូស្ត្រាលី (ស្មើនឹង ៣,០៧លានដុល្លាសហរដ្ឋអាមេរិក) ដល់ភាគីអន្តរជាតិនៃអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា សំរាប់ឆ្នាំ២០១៣។

**ឯកឧត្តម ព្រឹទ្ធសមាជិក បប់ ខារ** បានមានប្រសាសន៍ថា “អូស្ត្រាលីគឺជាប្រទេសផ្តល់ជំនួយធំជាងគេលំដាប់ទីពីរ និងជាអ្នកគាំទ្រដ៏យូរអង្វែងនិងរឹងមាំមួយ ចំពោះអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ការចូលរួមចំណែកថ្មីនេះ នាំអោយការគាំទ្រផ្នែកហិរញ្ញវត្ថុរបស់ប្រទេសអូស្ត្រាលីដល់អង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជាឈានដល់ចំនួនសរុប២៣លានដុល្លារអូស្ត្រាលី (ស្មើនឹង ២០,៩១លានដុល្លាសហរដ្ឋអាមេរិក) ដែលនឹងជួយធានាដល់តំណើរការបន្តរបស់តុលាការនេះ”។

“សាវនាការរបស់អង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា មានតួរនាទីយ៉ាងសំខាន់បំផុតក្នុងការស្វែងរកយុត្តិធម៌ជូនដល់ប្រជាពលរដ្ឋកម្ពុជាដែលបានទទួលរងគ្រោះដោយស្នាដៃខ្មែរក្រហម”។

“នៅរាជធានីភ្នំពេញកាលពីឆ្នាំមុន ខ្ញុំបានសំដែងនូវការស្វាគមន៍ចំពោះការបញ្ចប់សំណុំរឿងប្រឆាំងនឹងសមមិត្ត **ឌុច** អតីតមេគុកទួលស្លែងដ៏ល្បីល្បាញដែលប្រជាជនកម្ពុជាប្រមាណ១៥០០០នាក់ត្រូវបានបញ្ជូនទៅវាលពិឃាដនេះ”។

“បច្ចុប្បន្ននេះ អង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងតែជំនុំជំរះសំណុំរឿងប្រឆាំងនឹងអតីតថ្នាក់ដឹកនាំកំពូលនៃរបបខ្មែរក្រហមដែលកំពុងរស់រាននៅឡើយ។ ជនជាប់ចោទទាំងនោះត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ”។

‟ខ្ញុំសង្ឃឹមជឿជាក់ថា អង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធ្វើយ៉ាងណាអោយថ្នាក់ដឹកនាំកំពូលនៃរបបខ្មែរក្រហមទាំងនោះទទួលខុសត្រូវចំពោះអំពើរសាហាវយុងឃ្នងដែលបានប្រព្រឹត្តក្នុងនាមរបស់ពួកគេ״។

‟ប្រទេសអូស្ត្រាលីនឹងបន្តការលើកទឹកចិត្តអោយប្រទេសកម្ពុជាបន្តការទាក់ទាញដល់ម្ចាស់ជំនួយធំៗដ៏ទៃទៀត ដើម្បីធានាអោយបានការគាំទ្រយ៉ាងពេញលេញដល់អង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា តាមរយៈសំណុំរឿងដែលនៅសេសសល់״។

‟យើងខ្ញុំសង្ឃឹមថា រាជរដ្ឋាភិបាលកម្ពុជានឹងធានាបាននូវការចូលរួមចំណែករបស់ខ្លួនក្នុងថវិការរបស់អង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយប្រាក់បៀវត្សត្រូវបានបើកជូនដល់បុគ្គលឹកជាតិគ្រប់គ្នា ដោយយោងតាមមាត្រា១៥ នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយអង្គការសហប្រជាជាតិ״ ៕


*សំរាប់ពត៌មានបន្ថែមសូមទាក់ទង:*

លោក **ដេវ ហ្គោច** (Dave Gordge) អ្នកនាំពាក្យនៃស្ថានទូតអូស្ត្រាលី
ប្រចាំរាជធានីភ្នំពេញ

Email: dave.gordge@dfat.gov.au

ទូរស័ព្ទលេខ: ០២៣ ២១៣ ៤៧០ លេខបន្ត: ៥០២


ថ្ងៃទី១៨ ខែ មិថុនា ឆ្នាំ ២០១៣